**សុន្ទរកថា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងឱកាសបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារប្រចាំឆ្នាំ២០០៩**

**និងលើកទិសដៅការងារឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ**

**ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០**

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តម នាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ នាយនគរបាលជាតិ
- ឯកឧត្តមប្រធានក្រុមប្រឹក្សា ឯកឧត្តមអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គសន្និបាតទាំងមូលជាទីមេត្រី!

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាថ្មីម្តងទៀតជាមួយឯកឧត្តម លោកជំទាវ លោកស្រី អស់លោកក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅការងារឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃក្នុងឱកាសដ៏ថ្លៃថ្លានេះ ជាមួយការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិលនៃក្រសួងមហាផ្ទៃ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានរួមគ្នាធ្វើពលិកម្មយ៉ាងធំធេងក្នុងការសម្រេចបាននូវសមិទ្ធផលនានាជាច្រើនក្នុងឆ្នាំ២០០៩កន្លងទៅនេះ ។

ជាមួយសមិទ្ធផលទាំងនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលប្រឹងប្រែងរួមជាមួយថ្នាក់ដឹកនាំដទៃទៀតនៃក្រសួងមហាផ្ទៃ ក្នុងការដឹកនាំធ្វើឱ្យក្រសួងមហាផ្ទៃសម្រេចបាននូវសមិទ្ធផលទាំងនេះ ដែលក្នុងឱកាសនេះ ខ្ញុំសូមធ្វើការកត់សម្គាល់លើសមិទ្ធផលធំៗមួយចំនួនដូចខាងក្រោម :

**ទីមួយ :** ឆ្នាំ២០០៩កន្លងទៅ ទោះបីប្រទេសយើងបានទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុជាសកល គ្រោះធម្មជាតិបណ្តាលមកពីខ្យល់ព្យុះកេតសាណា ជម្ងឺផ្តាសាយ($A/H_1N_1$) ឥទ្ធិពលនៃបរិយាកាសសន្តិសុខក្នុងតំបន់ និងអន្តរជាតិ និងការប្រឈមចំពោះសកម្មភាពយោធាថៃនៅតំបន់ព្រំដែនភាគខាងលិច ពិសេសតំបន់ប្រាសាទ

ព្រះវិហារប្រាសាទតាមាន់ តំបន់មុំបី ...។ល។ ប៉ុន្តែក្រោមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃបានចូលរួមយ៉ាងសកម្មក្នុងការពុះពារជំនះឆ្លងកាត់បញ្ហាប្រឈមទាំងនេះធ្វើឱ្យប្រទេសយើងរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ ការពារបានយ៉ាងគត់មត់នូវអធិបតេយ្យ បូរណភាពទឹកដីរបស់ជាតិ បញ្ចៀសបាននូវសកម្មភាពភេរវកម្ម វិច្ឆេទកម្មនានា ធ្វើឱ្យជីវភាពសង្គមលើគ្រប់វិស័យប្រព្រឹត្តទៅមុខដោយរលូន។ ជាមួយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះពលិកម្ម និងវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ព និងនគរបាលរបស់យើង ដែលបាននឹងកំពុងធ្វើពលិកម្មយ៉ាងប្តូរផ្តាច់ ឈរជើងការពារបូរណភាពទឹកដីដ៏ពិសិដ្ឋរបស់យើង នៅតាមខ្សែបន្ទាត់ព្រំដែនភាគខាងលិច ព្រមជាមួយវប្បធម៌ចែករំលែករបស់សប្បុរសជនទាំងក្នុង និងក្រៅប្រទេស ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិកនៃក្រសួងស្ថាប័ន រាជធានី និងខេត្តនានា ដែលបានបរិច្ចាគធនធានផ្ទាល់របស់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យការអភិវឌ្ឍសង្គម ការការពារបូរណភាពទឹកដីនៅព្រំដែនភាគខាងលិច ការជួយទ្រទ្រង់ជាប្រចាំដល់ជីវភាពកងទ័ព និងនគរបាល ដែលកំពុងឈរជើងនៅទីនោះ ដែលនេះគឺជាការបង្ហាញនូវស្មារតី ទឹកចិត្ត សកម្មភាពស្នេហាជាតិមាតុភូមិ ជាមួយឆន្ទៈប្តេជ្ញាចិត្តដ៏មោះមុតរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាយើងទាំងមូល ក្នុងការរក្សាការពារឱ្យខាងតែបាននូវឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីរបស់ខ្លួន។

**ទីពីរ** : អំពីសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ក៏ត្រូវបានពង្រឹង និងគ្រប់គ្រងនៅគ្រប់ច្រកល្ហកនៃប្រទេសរបស់យើង។ កងកម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិបានប្រឹងប្រែងបង្កើនវិធានការតាមគ្រប់រូបភាពក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ការរក្សាសុវត្ថិភាពជាទូទៅក្នុងសង្គម ធ្វើឱ្យប្រជាជនយើងកាន់តែមានភាពកក់ក្តៅអំពីសុវត្ថិភាពផ្ទាល់ខ្លួន គ្រួសាររបស់ខ្លួន និងក្នុងសង្គមទាំងមូល។

ការរក្សាបានគត់មត់នូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមទាំងនេះ បានបង្កបរិយាកាសអនុគ្រោះដល់សកម្មភាពនៃធុរកិច្ច ការវិនិយោគ ការធានាដល់លំហូរនៃអ្នកទេសចរណ៍ ព្រមជាមួយការបង្កលក្ខណសម្បត្តិដល់ប្រទេសយើង ក្នុងការទទួលរៀបចំឱ្យមានព្រឹត្តិការណ៍ជាតិ អន្តរជាតិនានាជាច្រើន សម្រាប់គោលដៅនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ព្រមទាំងសកម្មភាពវប្បធម៌ ទេសចរណ៍ ...។ល។

**ទីបី** : ចំពោះកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងឆ្នាំ២០០៩កន្លងទៅនេះយើងសម្រេចបានសមិទ្ធផលថ្មីមួយទៀតជាប្រវត្តិសាស្ត្រ នោះគឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានដំណើរការទៅប្រកបដោយជោគជ័យ។ តាមរយៈការបោះឆ្នោតនេះ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមក រហូតមកទល់ពេលនេះ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល សុទ្ធតែមានក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង

តាមការបោះឆ្នោតសកល និងអសកល ដែលដំណើរការនេះបាននាំឱ្យមានតំណាងពីគណបក្សនយោបាយនានាចូលរួមនៅក្នុងក្រុមប្រឹក្សាទាំងនោះ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី។ នេះជាដំណើរការមួយសម្រាប់ធានាឱ្យមានអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ពិតប្រាកដ ដែលនេះគឺជាឆន្ទៈ និងជាសកម្មភាពដ៏ជាក់លាក់ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សំដៅពង្រឹងស្ថិរភាពនយោបាយ ស្ថិរភាពសង្គមក្នុងរយៈពេលវែង សម្រាប់ជាមូលដ្ឋានដ៏រឹងមាំក្នុងការអភិវឌ្ឍន៍សង្គម ប្រកបដោយចីរភាព និងមានសមធម៌។

បន្ទាប់ពីការបោះឆ្នោតនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រហូតមកទល់ពេលនេះ ក្រសួងមហាផ្ទៃតាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានខិតខំបំពេញកិច្ចការជាច្រើនក្នុងការជួយគាំទ្រដល់ការចាប់ផ្តើមបំពេញការងារនៃក្រុមប្រឹក្សាទាំងនោះ រួមទាំងការប្រឹងប្រែងបន្តគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការឱ្យដំណើរការកាន់តែមានប្រសិទ្ធភាពមួយកម្រិតថែមទៀត។

**ទីបួន** : ក្រៅពីសមិទ្ធផលខាងលើនេះ ក្រសួងមហាផ្ទៃ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងនគរបាលជាតិទាំងមូល ក៏បានខិតខំប្រឹងប្រែងសម្រេចបាននូវសមិទ្ធផលនានាជាច្រើនទៀត ក្នុងការបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងនឹងបទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស រួមទាំងស្ត្រី និងកុមារ ការចូលរួមបង្ការទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់ បទល្មើសនេសាទ ការគ្រប់គ្រងក្មេងទំនើង ការងារពន្ធនាគារ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការចលនាប្រជាជនឱ្យចូលរួមក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការដោះស្រាយទំនាស់នៅមូលដ្ឋាន រួមទាំងទំនាស់ដីធ្លីការបណ្តុះបណ្តាល ការកសាងសមត្ថភាព ធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពស្ថាប័ន អង្គភាពនានា ទាំងនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅថ្នាក់ក្រោមជាតិ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

សមិទ្ធផលដែលក្រសួងមហាផ្ទៃ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងនគរបាលជាតិសម្រេចបានក្នុងឆ្នាំ២០០៩កន្លងទៅនេះ ពិតជាបានរួមចំណែកយ៉ាងធំធេងក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងដំណើរឈានឆ្ពោះទៅសម្រេចបាននូវកម្មវិធីកំណែទម្រង់នានា ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីបន្តឱ្យមានកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ទោះបីវិនាសកម្មដែលបណ្តាលមកពីសង្គ្រាមស៊ីវិល អំពើប្រល័យពូជសាសន៍បន្សល់ទុកក្នុងសង្គមរបស់យើងមានទំហំធំធេង ប៉ុន្តែអាស្រ័យដោយសមិទ្ធផលលើគ្រប់វិស័យដែលរាជរដ្ឋាភិបាលបានប្រឹងប្រែងសម្រេចបានកន្លងមកក្នុងរយៈពេលដ៏ខ្លីបំផុត ប្រសិនប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿននានាបានបង្ហាញឱ្យយើងឃើញច្បាស់ថា

បច្ចុប្បន្នកម្ពុជាកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ ហើយកម្ពុជាយើងពិតជាមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលប្រឡូកដោយស្មើភាព និងស្មើសិទ្ធិ ក្នុងកិច្ចការតំបន់ និងពិភពលោក។ ប្រការនេះបានបង្ហាញច្បាស់ថា គោលនយោបាយ និងសកម្មភាពនានា ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រកាន់យក គឺពិតជាមានលក្ខណៈត្រឹមត្រូវ និងមានការឆ្លើយតបក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមរបស់ជាតិ និងប្រជាជនកម្ពុជា ដែលក្នុងឱកាសនេះ ខ្ញុំសូមលើកទឹកចិត្តដល់សមាជិក សមាជិកាទាំងអស់នៃរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ សូមបន្តពង្រឹងការប្តេជ្ញាចិត្តក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះជាបន្តទៀត។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ឆ្នាំ២០១០នេះ ទោះបីមានការវាយតម្លៃជាទូទៅថា សេដ្ឋកិច្ចពិភពលោកបានចាប់ផ្តើមងើបឡើងវិញពីវិបត្តិដ៏ធ្ងន់ធ្ងរនៃសេដ្ឋកិច្ច ហិរញ្ញវត្ថុជាសកលយ៉ាងណាក្តី ក៏ស្ថានភាពងើបឡើងនេះមានលក្ខណៈមិនស្មើគ្នាពីវិស័យមួយទៅវិស័យមួយ និងពីតំបន់មួយទៅតំបន់មួយ ហើយក្រុមប្រទេសក្រីក្រនៅតែជាប្រទេសដែលទទួលរងឥទ្ធិពលពីស្ថានភាពងើបឡើងមិនទាន់ស្មើគ្នានៃសេដ្ឋកិច្ច ហិរញ្ញវត្ថុពិភពលោកនេះ។ ទន្ទឹមនេះ បញ្ហាអាវុធនុយក្លេអ៊ែ បញ្ហាភេរវកម្មអន្តរជាតិ ចោរសមុទ្រ អសន្តិសុខនៅក្នុងប្រទេសមួយចំនួនមានលក្ខណៈចាក់ស្រេះកាន់តែសាំញ៉ាំ ពិសេសវិបត្តិនយោបាយដ៏ស្មុគស្មាញក្នុងព្រះរាជាណាចក្រថៃ និងការចិញ្ចឹមមហិច្ឆតារបស់មេដឹកនាំជ្រុលនិយមមួយចំនួនរបស់ថៃ ក្នុងការរំលោភមកលើបូរណភាពទឹកដី និងអធិបតេយ្យជាតិរបស់ព្រះរាជាណាចក្រកម្ពុជា រួមជាមួយឥទ្ធិពលដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ បានធ្វើឱ្យលេចឡើងនូវបញ្ហាប្រឈមថ្មីៗថែមទៀតសម្រាប់តំបន់របស់យើង និងសម្រាប់ពិភពលោកទាំងមូល ពិសេសគឺសម្រាប់ក្រុមប្រទេសដែលមានការអភិវឌ្ឍ តិចតួច។ ដោយឡែកសម្រាប់កម្ពុជាយើង ទោះតិចឬច្រើន យើងនឹងទទួលរងឥទ្ធិពលពីបញ្ហាប្រឈមទាំងនេះ មកលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍ ការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជន។

ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច សំដៅធានាដល់ការអនុវត្តគោលដៅនៃការកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ទាមទារឱ្យយើងមានវិធានការដោះស្រាយបញ្ហាប្រឈមនានាឱ្យបានសមស្រប ជំរុញដំណើរការកំណែទម្រង់នានា សំដៅធានាឱ្យមានកំណើនសេដ្ឋកិច្ច។ ក្នុងនោះក្រសួងមហាផ្ទៃ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងនគរបាលជាតិទាំងមូលមានការទទួលខុសត្រូវក្នុងការចូលរួមការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ការកែទម្រង់ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលក្នុងឱកាសនេះ ខ្ញុំសូមធ្វើការកត់សម្គាល់នូវវិធានការសំខាន់ៗមួយចំនួនដែលត្រូវអនុវត្តក្នុងឆ្នាំ២០១០នេះ ដូចខាងក្រោម ÷

**ទី១**-ក្រសួងមហាផ្ទៃ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកម្លាំងនគរបាលជាតិ រួមជាមួយ

ប្រជាជនយើងទាំងមូល ត្រូវបន្តធ្វើការប្តេជ្ញាចិត្តក្នុងការធ្វើពលិកម្មយ៉ាងប្តូរផ្តាច់ ដើម្បីរក្សាការពារឱ្យខាងតែបាននូវបូរណភាពទឹកដី អធិបតេយ្យជាតិរបស់យើង ដោយប្រឹងប្រែងរួមគ្នាក្នុងការអនុវត្តអនុសាសន៍របស់ខ្ញុំ ដែលបានប្រកាសកាលពីថ្ងៃទី០៦ ខែកុម្ភៈ កន្លងទៅថ្មីៗនេះ ក្នុងឱកាសសម្ពោធទីបញ្ជាការកងពលធំអន្តរាគមន៍លេខ៣។

**ទី២**-ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀតប្រកបដោយស្មារតីម្ចាស់ការខ្ពស់ជាប់ជានិច្ច ក្នុងការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ ព្រមជាមួយនឹងបរិយាកាសសន្តិសុខល្អគ្របដណ្តប់លើផ្ទៃប្រទេសទាំងមូល បង្កលក្ខណៈដល់ការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ។ល។ សំដៅជំរុញការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមកម្មវិធីនយោបាយដែលរាជរដ្ឋាភិបាលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់ខ្លួន។

ជានិច្ចកាល ត្រូវពង្រឹងសមត្ថភាពកងកម្លាំងសន្តិសុខឱ្យកាន់តែរឹងមាំគ្រប់មុខជំនាញ ពង្រីកទូលាយកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅប្រមែប្រមូលព័ត៌មានសន្តិសុខឱ្យបានកាន់តែមានប្រសិទ្ធភាព បង្ការទប់ស្កាត់ឱ្យខាងតែបាន មិនទុកឱ្យមានសកម្មភាពភេរវកម្មណាមួយកើតឡើងបំផ្លិចបំផ្លាញអាយុជីវិត ទ្រព្យសម្បត្តិ និងសេចក្តីសុខសាន្តរបស់ប្រជាជាតិយើង ក្នុងនោះត្រូវយកចិត្តទុកដាក់ដល់ការគ្រប់គ្រងជាតិផ្ទុះគ្រប់ប្រភេទឱ្យបានហ្មត់ចត់ត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរួមមាននីតិវិធីនៃការគ្រប់គ្រងគ្រឿងផ្ទុះសម្រាប់កងទ័ព នីតិវិធីគ្រប់គ្រងគ្រឿងផ្ទុះសម្រាប់វិស្វកម្មស៊ីវិល។ ក្រៅពីនេះ ក៏ត្រូវបង្កើនការតស៊ូប្រឆាំងនឹងសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនផ្សេងៗទៀត ដូចជាការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការលាងលុយកខ្វក់ ការជួញដូរអាវុធ ។ល។ ព្រមជាមួយនឹងការប្រុងប្រយ័ត្នចំពោះអសន្តិសុខនានា ដែលកើតឡើងពីផ្ទៃក្នុងជាតិផងដែរ។ ត្រូវចាត់វិធានការម៉ឺងម៉ាត់ ដើម្បីបង្កាទប់ស្កាត់ចំពោះសកម្មភាពកសាងកម្លាំងប្រដាប់អាវុធខុសច្បាប់ ការបំបែកបំបាក់សាមគ្គីភាពជាតិ និងការបង្កចលាចលសង្គមគ្រប់ប្រភេទដែលជាការរំខាន រាំងស្ទះដល់នយោបាយសន្តិភាវូបនីយកម្ម សុខដុមនីយកម្ម និងការអភិវឌ្ឍទឹកដី។

**ទី៣**-ត្រូវលើកកម្ពស់តួនាទីរបស់គណបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ក្នុងការរ៉ាប់រងដឹកនាំ និងទទួលខុសត្រូវក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ តាមបទពិសោធន៍កន្លងទៅថ្វីត្បិតតែក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិជាអ្នកបញ្ជាចាត់ចែង ដឹកនាំកិច្ចការរក្សាសន្តិសុខក៏ពិតមែន ប៉ុន្តែតួនាទីសំខាន់ គឺជាការដាក់ចេញនូវគោលនយោបាយ និងការចាត់ចែងកិច្ចការធំៗដែលហួសពីសមត្ថភាពរបស់រាជធានី ខេត្ត ឬជាកិច្ចការជំនាញស៊ីជំរៅតែប៉ុណ្ណោះ ដោយឡែកចំពោះការអនុវត្តជាក់ស្តែងសម្រាប់ថែរក្សានិរន្តរភាពសន្តិសុខ ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន គឺថ្នាក់មូលដ្ឋានជាអ្នកដែលនៅកៀកបំផុតជាមួយប្រជាពលរដ្ឋ ជាពិសេសគឺ គណបញ្ជាការឯកភាពដែលជាអ្នកមានលទ្ធភាពបំផុតក្នុងការកៀងគរកម្លាំងសរុប និងវិធានការសរុបឱ្យចូលរួមក្នុងចលនាការការពារសន្តិសុខមូលដ្ឋាន ព្រោះកិច្ចការនេះមិនអាចទុកឱ្យតែនគរបាល

ឬកងរាជអាវុធហត្ថធ្វើតែឯកឯងបានទេ គឺត្រូវមានការចូលរួមពីគ្រប់ថ្នាក់ គ្រប់ផ្នែក និងមានការចូលរួមពីប្រជាជនទើបទទួលបានជោគជ័យ ។

**ទី៤**-ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមអំពាវនាវដល់មន្ត្រីនគរបាលទាំងអស់ឱ្យយកចិត្តទុកដាក់ឱ្យកាន់តែប្រសើរថែមទៀតនូវការលើកកម្ពស់គុណធម៌ សីលធម៌ ក្នុងនាមជាកងកម្លាំងដែលមានភារកិច្ចបម្រើប្រជាពលរដ្ឋលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវខិតខំធ្វើអ្វីៗទាំងអស់ដើម្បីប្រជាពលរដ្ឋ ថែរក្សាការពារប្រជាពលរដ្ឋ និងមិនត្រូវធ្វើអ្វីដែលជាអំពើខុសឆ្គងប៉ះពាល់ដល់ប្រជាពលរដ្ឋឡើយ ។

ហាមដាច់ខាតការយកតួនាទី និងសិទ្ធិអំណាចរបស់នគរបាលដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ដូចជាការកាប់ព្រៃឈើ ការរុករានដីខុសច្បាប់ ការរកស៊ីជលផលខុសច្បាប់ ការរត់ពន្ធជាដើម ឬធ្វើជាខ្នងបង្អែកឱ្យឈ្មួញរកស៊ីខុសច្បាប់ ដើម្បីជាថ្នូរនឹងការទទួលបាននូវផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។

**ទី៥**-ជាមួយនឹងការកោតសរសើរ និងការថ្លែងអំណរគុណចំពោះមន្ត្រីនគរបាលជាច្រើនដែលបានខិតខំពលិកម្មកម្លាំងកាយ ចិត្ត អនុវត្តល្អភារកិច្ចស្នូលរបស់ខ្លួនក្នុងការរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គមដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែត្រូវបានលើកកម្ពស់ ហើយបទល្មើសបួនមានការថយចុះ គួរឱ្យកត់សម្គាល់នោះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំដាក់ចេញនូវបទបញ្ជាឱ្យមន្ត្រីនគរបាលមួយចំនួនតូចដែលកំពុងបំពេញភារកិច្ចនៅមូលដ្ឋាន ហើយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ បញ្ឈប់សកម្មភាពរបស់ខ្លួនជាបន្ទាន់ ហើយត្រូវលើកកម្ពស់ការខិតខំផ្តល់សេវាបម្រើប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើងវិញ ។

ក្នុងករណីមន្ត្រីនគរបាលណាដែលមិនព្រមបញ្ឈប់សកម្មភាព ឬកែប្រែសកម្មភាពរបស់ខ្លួន ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវអនុវត្តវិន័យឱ្យបានហ្មឺងម៉ាត់បំផុតចំពោះមន្ត្រីនគរបាលនោះ ។

ជាមួយនោះក៏សូមអំពាវនាវផងដែរដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស សូមមេត្តាចូលរួមទាំងអស់គ្នាដើម្បីសន្តិសុខ សណ្តាប់ធ្នាប់សង្គម ដូចជារាយការណ៍អំពីមុខសញ្ញាជនល្មើស ឬសកម្មភាពសង្ស័យណាមួយ ឬរាយការណ៍នៅពេលឃើញមានសកម្មភាពអសកម្មណាមួយកើតឡើង តាមរយៈការសរសេរសំបុត្រអនាមិកដាក់ក្នុងប្រអប់សំបុត្រនៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាល អធិការដ្ឋាននគរបាលខណ្ឌ ស្រុក ក្រុង ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬទូរស័ព្ទរាយការណ៍មកកម្លាំងប្រចាំបញ្ជានៅតាមស្នងការដ្ឋាននីមួយៗដែលបានជូនដំណឹងអំពីលេខទូរស័ព្ទ ឬមកអគ្គស្នងការដ្ឋាននគរបាលជាតិ និងតាមមធ្យោបាយផ្សេងៗទៀត ដើម្បីនគរបាលបានចុះទៅជួយបានទាន់ពេលវេលា ។

**ទី៦**-ត្រូវយកចិត្តទុកដាក់ជំរុញការអនុវត្តភារកិច្ចស្នូលរបស់នគរបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីកាត់បន្ថយបទល្មើសគ្រប់ប្រភេទ និងជំរុញលទ្ធភាពស្រាវជ្រាវ ស៊ើបអង្កេត រើកមុខជនល្មើស ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ ។

ឆ្លងតាមបទពិសោធន៍ក្នុងរយៈពេលខ្លី ចាប់ពីថ្ងៃទី០១ ខែសីហា មកដល់ថ្ងៃទី៣១ ខែធ្នូ ចុងឆ្នាំ២០០៩ នៅពេលដែលយើងចាប់ផ្តើមយុទ្ធនាការអនុវត្តច្បាប់ចរាចរផ្លូវគោក យើងបានធ្វើឱ្យមិនត្រឹមតែសណ្តាប់ធ្នាប់ចរាចរបានប្រែប្រួលរៀបរយប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមចំណែកយ៉ាងច្រើន ធ្វើឱ្យបទល្មើសប្លន់នៅតាមដងផ្លូវ និងទីសាធារណៈ ជាពិសេសការប្លន់ម៉ូតូមានការថយចុះ ដោយសារម៉ូតូដែលធ្លាប់តែធ្វើចរាចរគ្មានស្លាកលេខ គ្មានការចុះបញ្ជីគ្រប់គ្រង ពុំមានសិទ្ធិបើកបរលើផ្លូវ ហើយម្ចាស់ម៉ូតូបានទៅចុះបញ្ជីគ្រប់គ្រងស្ទើរគ្រប់ៗគ្នា ជាហេតុធ្វើឱ្យម៉ូតូដែលចោរធ្វើសកម្មភាពប្លន់ងាយនឹងត្រូវបានកំណត់អត្តសញ្ញាណ ហើយម៉ូតូដែលចោរប្លន់បានក៏ពិបាកនឹងរកទីផ្សារដើម្បីលក់ដូរដែរ ។ ជាក់ស្តែងតួរលេខបទល្មើសប្លន់ទោចក្រយានយន្ត រយៈពេល០៥ខែមុនអនុវត្តច្បាប់ចរាចរផ្លូវគោក និងរយៈពេល០៥ខែក្រោយអនុវត្តច្បាប់ បានបង្ហាញថាមានការថយចុះពីចំនួន១១២លើក មកនៅត្រឹម៥៤លើក ។

ខ្ញុំចង់និយាយថា ឆ្នាំ២០១០ ក្រសួងមហាផ្ទៃ ដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ ត្រូវជំរុញវិធានការមួយបន្ថែមទៀតឱ្យបានខ្លាំងក្លានោះ គឺការគ្រប់គ្រងមនុស្សឱ្យបានល្អ ព្រោះថាបើធ្វើបញ្ហានេះបាន គឺវិធានការអប់រំ ដើម្បីបង្កាទប់ស្កាត់បទល្មើស វិធានការបំបាត់ប្រសិទ្ធភាពជនខិលខូច និងវិធានការស្រាវជ្រាវស៊ើបអង្កេតរបស់នគរបាលពិតជានឹងកាន់តែមានប្រសិទ្ធភាព ហើយជនល្មើសនឹងខ្លាចរអារ ។

កន្លងមក ទាក់ទិននឹងបញ្ហាគ្រប់គ្រងមនុស្ស យើងមានអនុក្រឹត្យស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណ ប័ណ្ណស្នាក់នៅ និងប័ណ្ណគ្រួសារដែលជួយឱ្យនគរបាលក្តាប់បានមួយជំហាន ប៉ុន្តែយើងនៅស្ពុគស្មាញអំពីការគ្រប់គ្រងការស្នាក់នៅបណ្តោះអាសន្ន និងការប្រែប្រួលទីលំនៅរបស់ប្រជាពលរដ្ឋជាទូទៅ ដែលប្រការនេះ ខ្ញុំយល់ថាត្រូវតែពិចារណារដើម្បីកសាងបទដ្ឋាន ឬកសាងច្បាប់ សំដៅធ្វើយ៉ាងណាធានាការគ្រប់គ្រងសង្គមមួយឱ្យបានច្បាស់លាស់ ។

ទន្ទឹមនេះ ត្រូវជំរុញការគ្រប់គ្រងអាវុធជាតិផ្ទុះឱ្យបានល្អថែមទៀត បើទោះបីយើងធ្វើបានច្រើនរួចមកហើយក្តី ក៏នៅមានអាវុធរាយប៉ាយនៅឡើយ ដែលបញ្ហានេះក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិត្រូវសហការគ្នារៀបចំការបូកសរុប ដកពិសោធន៍រួមគ្នាមួយ ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវឱ្យកាន់តែមានប្រសិទ្ធភាព ។

**ទី៧**-ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏សូមធ្វើការកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះការខិតខំប្រឹងប្រែងយ៉ាងសកម្មរយៈពេលកន្លងទៅរបស់ក្រសួងមហាផ្ទៃ ដែលមានសាលាបណ្ឌិតសភានគរបាលជាសេនាធិការ និងអគ្គស្នងការដ្ឋាននគរបាលជាតិជាអ្នកចូលរួម បានបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីនគរបាលយ៉ាងច្រើនសន្ធឹកសន្ធាប់ ទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលបានធ្វើឱ្យកងកម្លាំងនេះមានការប្រែប្រួលគួរឱ្យកត់សម្គាល់ និងស្ថិតនៅក្នុងជំហានដ៏ល្អ ដើម្បីជំរុញឱ្យកងកម្លាំងនគរបាលទាំងមូលក្លាយជាកម្លាំងមួយប្រកបដោយសមត្ថភាពវិជ្ជាជីវៈពិតប្រាកដ និងមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ ។

ជាមួយនឹងការខិតខំប្រឹងប្រែងនេះ ខ្ញុំសូមស្នើឱ្យក្រសួងមហាផ្ទៃបន្តលើកកម្ពស់ និងតម្រង់ទិសការងារបណ្តុះបណ្តាល ធនធានមនុស្សឱ្យកាន់តែមានលទ្ធផលផ្លែផ្កាល្អថែមទៀត ទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់ដល់ការប្រើប្រាស់មន្ត្រីដែលបានបណ្តុះបណ្តាលរួចហើយឱ្យបានចំគោលដៅ និងត្រូវការរៀបចំយុទ្ធសាស្ត្រកសាងមន្ត្រីសម្រាប់បន្តវេនដើម្បីធានានូវនិរន្តរភាព និងប្រសិទ្ធភាពការងារ ។

**ទី៨**-អំពីការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងឆ្នាំ២០១០នេះ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការរៀបចំឡើងវិញនូវប្រព័ន្ធ និងរចនាសម្ព័ន្ធតាមថ្នាក់រដ្ឋបាលនីមួយៗ ដើម្បីឆ្លើយតបខ្សែគណនេយ្យភាពថ្មីនៃរដ្ឋបាលទាំងនោះ ស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

អាស្រ័យដោយដំណើរការកំណែទម្រង់នេះ បាននឹងកំពុងឈានមកដល់ដំណាក់កាលកាន់តែស៊ីជម្រៅ ហេតុនេះ ខ្ញុំសូមស្នើដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវជំរុញការពិនិត្យសេចក្តីព្រាងកម្មវិធីជាតិរយៈពេល១០ឆ្នាំ(២០១០-២០១៩) ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តកម្មវិធីជាតិនេះ សម្រាប់ឱ្យយើងទាំងអស់គ្នាមានភាពច្បាស់លាស់អំពីដំណាក់កាល និងសកម្មភាពសំខាន់ៗដែលត្រូវសម្រេចឱ្យបានក្នុងដំណាក់កាលនីមួយៗនៃកំណែទម្រង់ដ៏សំខាន់នេះ ។ ទន្ទឹមនេះ លើមូលដ្ឋាននៃកម្មវិធីជាតិនេះ ចាំបាច់ត្រូវរៀបចំឱ្យបាននូវសកម្មភាពរយៈពេល០៣ឆ្នាំដំបូងនៃការអនុវត្តកម្មវិធីជាតិ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីទំហំការងារ ការប៉ាន់ប្រមាណអំពីធនធានដែលមាន រួមទាំងធនធានពីរាជរដ្ឋាភិបាលពីដៃគូរអភិវឌ្ឍន៍ និងពីអ្នកពាក់ព័ន្ធនានា ។ ទន្ទឹមនេះ សកម្មភាពរយៈពេល៣ឆ្នាំនេះ ក៏ជាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ធ្វើសុខដុមនីយកម្មក្នុងចំណោមដៃគូរអភិវឌ្ឍន៍ និងសម្រាប់តម្រឹមការគាំទ្រពីដៃគូរអភិវឌ្ឍន៍ និងសង្គមស៊ីវិលចំពោះដំណើរការកំណែទម្រង់នេះផងដែរ ។

ក្នុងឆ្នាំ២០១០នេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវដំណើរការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលប្រចាំឆ្នាំ ជាមួយដំណើរការនៃការត្រៀមរៀបចំថវិកាឆ្នាំ២០១១ជាលើកដំបូងរបស់ខ្លួន ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ខិតខំរៀបចំលិខិតបទដ្ឋានសម្រាប់គាំទ្រដំណើរការនេះឱ្យបានទាន់ពេលវេលា ពិសេសច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវជំរុញការតាក់តែងលិខិតបទដ្ឋាន ចាំបាច់នានាជាច្រើនទៀត សម្រាប់អនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់ការបំពេញការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃថ្នាក់រដ្ឋបាលទាំងនេះ ស្របតាមច្បាប់រៀបចំអង្គការ រួមទាំងការខិតខំធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរាជការនៃថ្នាក់

រដ្ឋបាលទាំងនេះ អំពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការថ្មី ទំនាក់ទំនងការងារថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

បញ្ហាស្នូលសំខាន់នៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ទាមទារឱ្យមានការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ បុគ្គលិក សមត្ថភាពរូបវ័ន្ត និងសមត្ថភាពតាមផ្លូវច្បាប់ដែលតម្រូវឱ្យមានការគិតគូររៀបចំលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនានាក្លាយជាស្ថាប័នដែលមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍ ស្របតាមតម្រូវការរបស់មូលដ្ឋាន សំដៅចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ នេះគឺជាដំណើរការមួយ ដ៏រសើប និងមានលក្ខណៈសាំញ៉ាំ ដែលទាមទារឱ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវពង្រឹងការប្តេជ្ញាចិត្តខាងនយោបាយ ដែលយើងទាំងអស់គ្នាបានឯកភាពស្រុះស្រួលគ្នាតាំងពីដំណាក់កាលដំបូងមក ដើម្បីបន្តជំរុញដំណើរការកំណែទម្រង់នេះ ឱ្យសម្រេចបានសមិទ្ធផលតាមការគ្រោងទុកក្នុងដំណាក់កាលដ៏សំខាន់នេះ ។

**ទី៩**-ដោយសារមានតម្រូវការជាច្រើនក្នុងការគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនាដំណាក់កាលដំបូងៗនេះ ហេតុនេះ យើងមិនត្រូវមើលរំលងដល់ការបន្តពង្រឹងនូវដំណើរការកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ឡើយ ។ ឃុំ សង្កាត់ត្រូវបានចាត់ទុកជាគ្រឹះនយោបាយដ៏សំខាន់ក្នុងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិទាំងមូល ដោយសារតែក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានប្រជាជនបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ ។ ប្រការនេះ ចាំបាច់ត្រូវរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធដ៏សមស្របមួយសម្រាប់ថ្នាក់ជាតិ និងសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជួយគាំទ្រ និងឆ្លើយតបតម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីជួយឱ្យឃុំ សង្កាត់ក្នុងការឆ្លើយតបដោយផ្ទាល់ចំពោះតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ។ អាស្រ័យដោយសារៈសំខាន់នៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ ទាំងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិល បានបង្ហូរធនធានកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំដល់ថ្នាក់ឃុំ សង្កាត់ ដើម្បីឱ្យឃុំ សង្កាត់ធ្វើការវិនិយោគទៅលើគម្រោងអភិវឌ្ឍន៍ខ្នាតតូចៗនៅមូលដ្ឋាន ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើនការជួយគាំទ្រដល់ឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងទាំងនោះឱ្យមានប្រសិទ្ធភាពស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ មន្ត្រីគ្រប់ថ្នាក់ដែលត្រូវបានប្រគល់ តួនាទីក្នុងការជួយគាំទ្រឃុំ សង្កាត់ ត្រូវរក្សាឱ្យបាននូវគោលការណ៍ស្វ័យភាពរបស់ឃុំ សង្កាត់ និងត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍សុចរិតភាពខ្ពស់បំផុតក្នុងការជួយគាំទ្រដល់គម្រោងអភិវឌ្ឍន៍នានានៅមូលដ្ឋាន ។

**ទី១០**-ក្នុងឆ្នាំ២០១០នេះ អាស្រ័យដោយតម្រូវការនៃការកែទម្រង់ ដែលទាមទារឱ្យមានការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ដែលនាំឱ្យប៉ះពាល់ដល់ការរៀបចំឡើងវិញនូវមន្ត្រី

រាជការនានានៅថ្នាក់ក្រោមជាតិ ពិសេសមន្ត្រីរាជការដែលបម្រើការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ហេតុនេះ ក្នុងដំណាក់កាលនេះ ចាំបាច់ត្រូវខិតខំរក្សាឱ្យបាននូវនិរន្តរភាពការងារគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ និងត្រូវបន្តលើកកម្ពស់ប្រសិទ្ធភាពក្នុងការឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយផ្តោតការយកចិត្តទុកដាក់ដល់ក្រុមជនងាយរងគ្រោះនានា ព្រមទាំងត្រូវបន្តខិតខំដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន ដូចជាការបន្តលើកកម្ពស់វិធានការក្នុងការបង្ការទប់ស្កាត់បង្ក្រាបបទល្មើសនានានៅមូលដ្ឋាន ពិសេសការកាប់ព្រៃឈើ ការកាប់រានដីព្រៃដោយខុសច្បាប់ ការសម្របសម្រួលដោះស្រាយទំនាស់នៅមូលដ្ឋាន ការគ្រប់គ្រងក្រុមក្មេងទំនើង ដើម្បីបង្កើនភាពកក់ក្តៅជូនប្រជាពលរដ្ឋ ក្នុងការធ្វើសកម្មភាពនានាក្នុងសង្គម ប្រកបដោយបរិយាកាសកក់ក្តៅ ជាមួយសុវត្ថិភាពយ៉ាងល្អប្រសើរ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ខាងលើនេះ ជាអនុសាសន៍របស់ខ្ញុំបន្ថែមពីលើទិសដៅការងារសម្រាប់ឆ្នាំ២០១០របស់ក្រសួងមហាផ្ទៃ ដែលអ្នកទាំងអស់គ្នាបានពិភាក្សា និងព្រមព្រៀងគ្នាក្នុងអង្គសន្និបាតនេះ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានជំនឿជឿជាក់លើឆន្ទៈ និងការប្តេជ្ញាចិត្តរបស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក និងសហការីទាំងអស់របស់ក្រសួងមហាផ្ទៃ ទាំងមន្ត្រីរដ្ឋបាលស៊ីវិល និងនគរបាលជាតិ ក្នុងការប្រឹងប្រែងសម្រេចបាន ប្រកបដោយជោគជ័យនូវអនុសាសន៍របស់ខ្ញុំ រួមទាំងទិសដៅការងារក្នុងឆ្នាំ២០១០នេះ ដើម្បីវឌ្ឍនភាព និងវិបុលភាពរបស់ប្រជាជាតិ និងប្រជាជនកម្ពុជា។

ជាមួយភាពជឿជាក់នេះ ជាថ្មីម្តងទៀត ខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តីជាមួយពរជ័យ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជូនចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ និងសូម **ប្រកាសបិទសន្និបាត**បូកសរុបការងារឆ្នាំ២០០៩ និងទិសដៅការងារឆ្នាំ២០១០របស់ក្រសួងមហាផ្ទៃក្នុងឱកាសនេះ។

**សូមអរគុណ!**